អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥

# សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

ការិយាល័យសហចៅក្រមស៊ើបអង្កេតកំពុងស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលចោទប្រកាន់លើការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិនានាដែលប្រទេសកម្ពុជាទទួលស្គាល់។ ការរំលោភយ៉ាងធ្ងន់ធ្ងរទាំងនេះ ត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ អនុលោមតាមវិធានផ្ទៃក្នុងជាធរមានរបស់ អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបអង្កេតអាចស្នើសុំឱ្យរដ្ឋមិនមែនជាភាគីនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ផ្តល់ការជួយជ្រោមជ្រែងតាមផ្លូវតុលាការជូនដល់ អ.វ.ត.ក បាន។

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្ហាញការពិតនៃការចោទប្រកាន់នៅក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្ញើលិខិតចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិចំនួនបីច្បាប់ជូនសាធារណរដ្ឋសង្គមនិយមវៀតណាម នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ដោយក្នុងនោះបានស្នើសុំឱ្យជួយជ្រោមជ្រែងផ្តល់ឯកសារពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ និងផ្តល់លទ្ធភាពចូលពិនិត្យមើលបណ្ណសារដែលអាចមានឯកសារទាំងនេះ។ នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្ញើលិខិតចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិចំនួនពីរច្បាប់ទៀតជូនព្រះរាជាណាចក្រថៃ ដោយក្នុងនោះស្នើសុំការជួយជ្រោមជ្រែងស្រដៀងគ្នា។ នៅក្នុងឆ្នាំ ២០១៤ និងឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសរសេរលិខិតផ្ញើជូនរដ្ឋាភិបាលទាំងពីរក្នុងគោលបំណងសុំឱ្យអនុវត្តតាមសំណើសុំការជួយជ្រោមជ្រែងចាំបាច់ទាំងនេះ។ ផ្ទុយទៅវិញ ការខិតខំប្រឹងប្រែងទាំងនេះពុំទទួលបានផ្លែផ្កានោះឡើយ។

មកទល់ពេលបច្ចុប្បន្ន ទាំងសាធារណរដ្ឋសង្គមនិយមវៀតណាម និងព្រះរាជាណាចក្រថៃពុំបានសហការជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ។ រដ្ឋាភិបាលទាំងពីរខកខានពុំបានផ្តល់ឯកសារពាក់ព័ន្ធដែលអាចជួយដល់កិច្ចស៊ើបសួរទាំងនេះឡើយ ហើយក៏ពុំបានអនុញ្ញាតឱ្យអ្នកស៊ើបអង្កេតពីការិយាល័យសហចៅក្រមស៊ើបអង្កេតមានលទ្ធភាពចូលពិនិត្យបណ្ណសារដូចបានកំណត់យ៉ាងជាក់លាក់ដែលអាចមានឯកសារពាក់ព័ន្ធផងដែរ។

ដើម្បីជាផលប្រយោជន៍ក្នុងការស្វែងរកយុត្តិធម៌ ការិយាល័យសហចៅក្រមស៊ើបអង្កេតសូមជំរុញឱ្យសាធារណរដ្ឋសង្គមនិយមវៀតណាម និងព្រះរាជាណាចក្រថៃអនុវត្តឱ្យបានពេញលេញតាមសំណើសុំការជួយជ្រោមជ្រែងចាំបាច់ទាំងនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោក **ឡាស អលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh




Original EN: 01117739-01117740